ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រស្ថិតិ
# សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ប្រចាំត្រីមាសទី២ ឆ្នាំ២០២៣


អគ្គនាយកដ្ឋានគោលនយោបាយ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


ខែសីហា ឆ្នាំ ២០២៣

# មាតិកា

សេចក្តីអធិប្បាយសង្ខេប ..................................................១

តារាងស្ថិតិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ..................................................៤

១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ..................................................៤

២. សូចនាករតាមវិស័យ.................................................. ៦

២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ .................................................. ៦

២.២. អត្រាប្តូរប្រាក់..................................................៧

២.៣. ស្ថានភាពហិរញ្ញវត្ថុសាធារណៈ .................................................. ៨

២.៤. ស្ថានភាពរូបិយវត្ថុ និងឥណទាន..................................................១០

២.៥. ស្ថានភាពពាណិជ្ជកម្ម..................................................១៤

២.៦. ស្ថានភាពវិនិយោគឯកជន..................................................១៨

២.៧. ស្ថានភាពទេសចរណ៍..................................................១៩

២.៨. ស្ថានភាពសំណង់ .................................................. ២១

៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ .................................................. ២២

# សេចក្តីអធិប្បាយសង្ខេប

ស្ថានភាពសេដ្ឋកិច្ចសកល ត្រូវបានវាយតម្លៃដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) កាលពីខែកក្កដា ឆ្នាំ២០២៣ បង្ហាញថា កំណើននឹងសម្រេចបាន ៣% នៅឆ្នាំ២០២៣ ខ្ពស់ជាងកំណើនព្យាករ នៅខែមេសា ឆ្នាំ២០២៣ កន្លងទៅ បន្តិចបន្តួច។ ការកើនឡើងនេះ គឺដោយសារការថមថយនៃអត្រាអតិផរណាសកល និងការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចជារួម។ ជាមួយគ្នានេះ ស្ថានភាពសេដ្ឋកិច្ចសកល ក៏នៅតែប្រឈមនឹងភាពមិនប្រាកដប្រជាមួយចំនួន ដូចជា ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ, អត្រាអតិផរណាគោលនៅតែស្ថិតក្នុងកម្រិតខ្ពស់, លក្ខខណ្ឌមិនសូវអំណោយផលក្នុងវិស័យហិរញ្ញវត្ថុ, សង្គ្រាមនៅអ៊ុយក្រែនបន្តអូសបន្លាយ និងភាពតានតឹងភូមិសាស្ត្រនយោបាយក្នុងតំបន់និងសកល។

ទន្ទឹមនេះ សេដ្ឋកិច្ចកម្ពុជា ត្រូវបានប៉ាន់ស្មានថានឹងសម្រេចបានក្នុងអត្រា ៥,៦% នៅឆ្នាំ២០២៣នេះ ដែលខ្ពស់ជាងឆ្នាំ២០២២កន្លងទៅ។ ការកើនឡើងនេះ គឺគាំទ្រដោយការរក្សាបានកំណើនល្អ នៃកម្មន្តសាលមិនមែនកាត់ដេរ ដែលបម្រើឱ្យការនាំចេញ និងការប្រើប្រាស់ក្នុងស្រុក, ការកើនឡើងនូវគម្រោងវិនិយោគធំៗ, ការងើបឡើងវិញនៃសំណើសាងសង់សំណង់ និងការងើបឡើងវិញគួរឱ្យកត់សម្គាល់នៃវិស័យទេសចរណ៍ តាមរយៈការកើនភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិ។ ជាការសង្កេត សកម្មភាពសេដ្ឋកិច្ចខ្លះនៅទ្រឹង និងខ្លះទៀតថមថយ ជាពិសេស ការនាំចេញផលិតផលកាត់ដេរ។ ដោយឈរលើមូលដ្ឋាននៃស្ថានភាពសូចនាករសំខាន់ៗ ក្នុងត្រីមាសទី២ ឆ្នាំ២០២៣ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន បានបង្ហាញថា ស្ថានភាពសេដ្ឋកិច្ចភាពល្អប្រសើរ ដែលស្តែងតាមរយៈ ការកើនឡើងចំនួនភ្ញៀវទេសចរអន្តរជាតិប្រមាណជាង ២៧១%, ការកើនឡើងទុនគម្រោងសាងសង់ប្រមាណ ១៣០,២%, ការកើនឡើងនៃទុនវិនិយោគប្រមាណ ៦៣,៣%, ការកើនឡើងនៃទំហំទំនិញនាំចេញមិនរាប់បញ្ចូលមាស ប្រមាណ ០,១%, ការកើនឡើងនៃអត្រាប្តូរប្រាក់ជាមធ្យមប្រមាណ ១,២%, ការកើនឡើងក្នុងកម្រិតទាបនៃសន្ទស្សន៍ថ្លៃទំនិញត្រឹមប្រមាណ ០,៥% និង ការថយចុះថ្លៃប្រេងឆៅប្រមាណជាង ៣០%។

**អតិផរណា និង អត្រាប្តូរប្រាក់**[1] អតិផរណាមធ្យមប្រចាំត្រីមាសទី២ ឆ្នាំ២០២៣ មានអត្រា ០,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ និងទាបជាងត្រីមាសមុនៗ ដោយសារការថមថយសន្ទស្សន៍ថ្លៃម្ហូបអាហារ និងការធ្លាក់ចុះសន្ទស្សន៍ថ្លៃភោជនីយដ្ឋាន, ប្រេងឥន្ធនៈ និងឧស្ម័ន (Gas) ជាដើម។ ទន្ទឹមនេះ អត្រាប្តូរប្រាក់ជាមធ្យមក្នុងរង្វង់ ៤ ១០៤ រៀល/ដុល្លារអាម៉េរិក បានកើនឡើង ១,២%។

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ**[2] នៅត្រីមាសទី២ ឆ្នាំ២០២៣ ការប្រមូលចំណូល អនុវត្តបានសរុបចំនួន ៦ ៤១៨,២ ប៊ីលានរៀល (ស្មើ ២៤,៨% នៃច្បាប់ថវិកាប្រចាំឆ្នាំ) បានធ្លាក់ចុះ ១៣,១% ក្នុងនោះ ចំណូលចរន្តសរុប ៦ ៤០១,៤ ប៊ីលានរៀល បានធ្លាក់ចុះ ១៣,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ដោយសារការធ្លាក់ចុះនៃការប្រមូលចំណូលសារពើពន្ធ ជាពិសេសពន្ធលើប្រាក់ចំណេញ, ចំណូលពន្ធអាករពិសេស និងចំណូលពន្ធលើការនាំចូល។ រីឯ ចំណាយសរុបអនុវត្តបានចំនួន ៧ ៥០៧,៤ ប៊ីលានរៀល (ស្មើនឹង ២១,៦% នៃច្បាប់ថវិកាប្រចាំឆ្នាំ) បានកើនឡើង ២៥,៦% ក្នុងនោះ ចំណាយចរន្តសរុបអនុវត្តបានចំនួន ៤ ៥០០,៥

[1] ទិន្នន័យពីវិទ្យាស្ថានជាតិស្ថិតិ/ក្រសួងផែនការ និងធនាគារជាតិ នៃកម្ពុជា

[2] ទិន្នន័យពីអគ្គនាយកដ្ឋានគោលនយោបាយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប៊ីលានរៀល បានកើនឡើង ២១,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ ជាលទ្ធផលនៃការអនុវត្តថវិកាចរន្ត មានអតិរេកចំនួន ១ ៩០០,៩ ប៊ីលានរៀល។

**ស្ថានភាពរូបិយវត្ថុ និងឥណទាន**[3]

គិតត្រឹមត្រីមាសទី២ ឆ្នាំ២០២៣ រូបិយវត្ថុទូទៅ (M2) មានសរុបចំនួន ១៨២,៥ ទ្រីលានរៀល បានកើនឡើង ៩,២% ខណៈទុនបម្រុងរូបិយបណ្ណបរទេសដុល មានសរុបចំនួន ១៨,៤ ប៊ីលានដុល្លារអាម៉េរិក បានធ្លាក់ចុះ ៥,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ ទន្ទឹមនេះ ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជ មានសរុបចំនួន ១៩៨,៥ ទ្រីលានរៀល បានកើនឡើង ១០,១% ដែលភាគច្រើនបានគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច ដូចជា ការលក់ដុំ-លក់រាយ, ការជួញដូរអចលនទ្រព្យ, ការសាងសង់ និងកសិកម្ម ជាដើម។

**ពាណិជ្ជកម្មក្រៅប្រទេស**[4]

នៅត្រីមាសទី២ ឆ្នាំ២០២៣ បើមិនរាប់បញ្ចូលមាស, ការនាំចេញ មានទឹកប្រាក់សរុបចំនួន ៥ ៦១៦,១ លានដុល្លារអាម៉េរិក បានកើនឡើង ០,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២ ដោយសារការកើនឡើងនៃការនាំចេញ បន្ទះសូឡានិងឌីយ៉ូត, រោមសត្វ, គ្រឿងអេឡិចត្រូនិក, គ្រឿងបន្លាស់រថយន្ត, និងផលិតផលកសិកម្ម ដូចជាអង្ករ, ស្វាយ, ស្វាយចន្ទី និងស្ករស ជាដើម។ រីឯ ការនាំចូល មានទឹកប្រាក់សរុបចំនួន ៦ ៣៦៩ លានដុល្លារអាម៉េរិក បានធ្លាក់ចុះ ៧% ដោយសារការធ្លាក់ចុះ នៃការនាំចូលក្រណាត់, គ្រឿង សំណង់, ប្រេងឥន្ធនៈ និងយានយន្ត។

**ទេសចរណ៍**[5]

នៅត្រីមាសទី២ ឆ្នាំ២០២៣ ភ្ញៀវទេសចរអន្តរជាតិ មានសរុបចំនួន ១,៣ លាននាក់ បានកើនឡើងប្រមាណ ៣ ដង ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ កំណើននេះ គឺដោយសារមានការប្រារព្ធឡើងនូវព្រឹត្តិការណ៍ជាតិធំៗជាប្រវត្តិសាស្ត្រ ដូចជាព្រឹត្តិការណ៍កីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ព្រមទាំងការដាក់ចេញវិធានការបន្ថែមសម្រាប់បន្តការគ្រប់គ្រងផលប៉ះពាល់ និងបន្តគាំទ្រដល់វិស័យទេសចរណ៍។

**វិនិយោគឯកជន**[6]

នៅត្រីមាសទី២ ឆ្នាំ២០២៣ គម្រោងវិនិយោគដែលបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសរុបចំនួន ៧៤ គម្រោង បានកើនឡើង ២៣ គម្រោង ស្មើនឹង ៤៥,១% និងទុនវិនិយោគមានសរុបចំនួន ៧៦០,២ លានដុល្លារអាម៉េរិក បានកើនឡើង ៦៣,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។ ការកើនឡើងនេះ គឺដោយមានការកើនឡើងគម្រោងវិនិយោគលើការចិញ្ចឹមសត្វ, ការកែច្នៃចំណីអាហារ, ការកែច្នៃដំឡូងមី, ការកែច្នៃចេក, ការអភិវឌ្ឍលើដែនកោះ, មជ្ឈមណ្ឌលទេសចរណ៍ និងការពង្រីកគម្រោងក្នុងតំបន់សេដ្ឋកិច្ចពិសេស ជាដើម។

---

[3] ទិន្នន័យពីធនាគារជាតិ នៃកម្ពុជា

[4] ទិន្នន័យពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

[5] ទិន្នន័យពីក្រសួងទេសចរណ៍

[6] ទិន្នន័យពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

**សំណង់**[7]

នៅត្រីមាសទី២ ឆ្នាំ២០២៣ គម្រោងសំណង់ទូទាំងប្រទេស មានសរុបចំនួន ៨២៦ គម្រោង បានធ្លាក់ចុះ ១៧៣ គម្រោង ស្មើនឹង ១៧,៣% ប៉ុន្តែទុនវិនិយោគ មានសរុបចំនួន ១ ៤៧៥ លានដុល្លារអាម៉េរិក បានកើនឡើង ១៣០,២% ក្នុងនោះ សំណង់លំនៅឋានមានចំនួន ៦០៧,៥ លានដុល្លារអាម៉េរិក, សំណង់ឧស្សាហកម្មមានចំនួន ៥៦៨,៥ លានដុល្លារអាម៉េរិក, សំណង់ពាណិជ្ជកម្មមានចំនួន ២៤៩ លានដុល្លារអាម៉េរិក, សំណង់សាធារណៈមានចំនួន ៨៧,១ លានដុល្លារអាម៉េរិក និងសំណង់ទេសចរណ៍មានចំនួន ៧៩,៦លានដុល្លារអាម៉េរិក។

**ថ្លៃទំនិញសំខាន់ៗ**[8] **លើទីផ្សារអន្តរជាតិ**

នៅត្រីមាសទី២ ឆ្នាំ២០២៣ ថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិគិតជាមធ្យម ដូចជា ថ្លៃប្រេងឆៅ ៧៦,៦ ដុល្លារអាម៉េរិក/ធុង បានធ្លាក់ចុះ ៣០,៤%, ថ្លៃកៅស៊ូ (TSR20) ១ ៣៤២,៥ ដុល្លារអាម៉េរិក/តោន បានធ្លាក់ចុះ ១៨,៧%, សន្ទស្សន៍ថ្លៃថាមពល ១០០,៥ បានធ្លាក់ចុះ ៣៧,៩%, សន្ទស្សន៍ថ្លៃមិនមែនថាមពល ១១២,៤ បានធ្លាក់ចុះ ១៦% ប៉ុន្តែ ថ្លៃមាស ២ ១៧០,៤ ដុល្លារអាម៉េរិក/អោន បានកើនឡើង ៥,៦%, អង្ករ ៥០៨,៣ ដុល្លារអាម៉េរិក/តោន បានកើនឡើង ១៣,៩% និងសន្ទស្សន៍ថ្លៃលោហធាតុមានតម្លៃ ១៥០,៥ បានកើនឡើង ៥,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។

[7] ទិន្នន័យពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

[8] ទិន្នន័យពីគេហទំព័រធនាគារពិភពលោក និងសម្គាល់÷សន្ទស្សន៍ថ្លៃថាមពល (ធ្យូងថ្ម, ប្រេងឆៅ និងឧស្ម័ន), មិនមែនថាមពល (លោហធាតុ, កសិកម្ម និងជីគីមី) និងលោហធាតុមានតម្លៃ (មាស, ប្រាក់ និងប្លាទីន)

# តារាងស្ថិតិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង ១÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| បរិយាយ | ឯកតា | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| **សូចនាករម៉ូលដ្ឋាន** | | | | | |
| អតិផរណា (ជាមធ្យម) | % | 2.8% | 7.4% | 0.5% | |
| អត្រាប្តូរប្រាក់ (ជាមធ្យម) | រៀល/ ដុល្លារអាម៉េរិក | 4,063.00 | 4,056.07 | 4,103.64 | 1.2% |
| **ហិរញ្ញវត្ថុសាធារណៈ** | | | | | |
| ចំណូលចរន្ត | ប៊ីលានរៀល | 5,439.60 | 7,376.42 | 6,401.44 | -13.2% |
| ចំណាយចរន្ត | ប៊ីលានរៀល | 3,685.35 | 3,712.86 | 4,500.54 | 21.2% |
| តុល្យភាពថវិកាចរន្ត | ប៊ីលានរៀល | 1,754.25 | 3,663.56 | 1,900.90 | -48.1% |
| **រូបិយវត្ថុ និងឥណទាន** | | | | | |
| រូបិយវត្ថុទូទៅ (M2) | ប៊ីលានរៀល | 147,952.45 | 167,112.21 | 182,492.82 | 9.2% |
| ឥណទាន* | ប៊ីលានរៀល | 174,767.50 | 216,020.19 | 238,741.74 | 10.5% |
| ឥណទេយ្យក្នុងស្រុក | ប៊ីលានរៀល | 146,697.61 | 186,982.35 | 208,949.94 | 11.7% |
| ទុនបម្រុងរូបិយបណ្ណបរទេសសុទ្ធ | លានដុល្លារអាម៉េរិក | 20,233.82 | 19,525.17 | 18,375.78 | -5.9% |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | | |
| ទំហំនាំចេញទំនិញ | លានដុល្លារអាម៉េរិក | 3,947.87 | 5,662.30 | 6,072.47 | 7.2% |
| ទំហំនាំចូលទំនិញ | លានដុល្លារអាម៉េរិក | 6,661.78 | 8,418.80 | 6,369.05 | -24.3% |
| តុល្យភាពពាណិជ្ជកម្ម | លានដុល្លារអាម៉េរិក | (2,713.91) | (2,756.50) | (296.58) | -89.2% |
| **វិនិយោគឯកជន** | | | | | |
| គម្រោងវិនិយោគសរុប | គម្រោង | 38 | 51 | 74 | 45.1% |
| ទុនវិនិយោគ | លានដុល្លារអាម៉េរិក | 638.33 | 465.47 | 760.17 | 63.3% |
| **ទេសចរណ៍** | | | | | |
| ភ្ញៀវទេសចរអន្តរជាតិ | នាក់ | 31,659 | 347,216 | 1,288,393 | 271.1% |
| **សំណង់ទូទាំងប្រទេស** | | | | | |
| គម្រោង | គម្រោង | 1,169 | 999 | 826 | -17.3% |

| បរិយាយ | ឯកតា | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| តម្លៃ | លានដុល្លារអាម៉េរិក | 862.65 | 640.60 | 1,474.95 | 130.2% |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ (ជាមធ្យម)** | | | | | |
| អង្ករ (បាក់៥%) | ដុល្លារអាម៉េរិក/ តោន | 484.67 | 446.33 | 508.33 | 13.9% |
| ប្រេងឆៅ** | ដុល្លារអាម៉េរិក/ ធុង | 67.05 | 110.10 | 76.62 | -30.4% |
| កៅស៊ូ (TSR20) | ដុល្លារអាម៉េរិក/ តោន | 1,657.27 | 1,652.10 | 1,342.47 | -18.7% |
| មាស | ដុល្លារអាម៉េរិក/ អោន | 1,991.26 | 2,056.01 | 2,170.44 | 5.6% |

ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិនៃកម្ពុជា

សម្គាល់÷ * ឥណទានផ្ដល់ដោយធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុ, ** ថ្លៃជាមធ្យមរួមប្រេងឆៅ÷ Brent, WTI និង Dubai

# ២. សូចនាករតាមវិស័យ

## ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង ២÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាស)*

| បរិយាយ | ត្រីមាសទី២ | ការប្រែប្រួល |
|---|---|---|

| | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
|---|---|---|---|---|
| **មុខទំនិញគ្រប់មុខ** | **186.57** | **200.42** | **201.47** | **0.5%** |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 231.24 | 245.32 | 250.63 | 2.2% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | 176.99 | 179.45 | 182.33 | 1.6% |
| សម្លៀកបំពាក់ និងស្បែកជើង | 160.50 | 175.98 | 179.71 | 2.1% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 131.32 | 142.59 | 140.76 | -1.3% |
| គ្រឿងសង្ហារិម សម្ភារប្រើប្រាស់ និងការថែទាំ | 154.25 | 161.13 | 162.72 | 1.0% |
| សុខាភិបាល | 138.34 | 143.18 | 143.17 | 0.0% |
| ការដឹកជញ្ជូន | 116.33 | 136.99 | 126.30 | -7.8% |
| គមនាគមន៍ | 66.44 | 66.61 | 66.53 | -0.1% |
| ការកំសាន្ត និងវប្បធម៌ | 120.36 | 128.85 | 131.58 | 2.1% |
| ការសិក្សា | 165.10 | 168.96 | 171.17 | 1.3% |
| ភោជនីយដ្ឋាន | 297.20 | 325.79 | 324.70 | -0.3% |
| ទំនិញ និងសេវាកម្មផ្សេងៗ | 160.16 | 168.01 | 170.23 | 1.3% |

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ (ឆ្នាំគោល ២០០៦)

*រូបភាព ១÷ ស្ថានភាពអតិផរណា (មធ្យមប្រចាំត្រីមាស)*




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.២. អត្រាប្តូរប្រាក់

*តារាង ៣÷ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*

| អត្រាប្តូរប្រាក់មធ្យមប្រចាំខែ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2015 | 4,042.67 | 4,055.67 | 4,092.00 | 4,050.67 |
| 2016 | 4,022.67 | 4,054.67 | 4,094.38 | 4,041.72 |
| 2017 | 4,016.14 | 4,047.37 | 4,079.54 | 4,037.16 |
| 2018 | 4,011.98 | 4,046.47 | 4,073.46 | 4,047.26 |
| 2019 | 4,006.33 | 4,052.39 | 4,086.61 | 4,063.09 |
| 2020 | 4,064.19 | 4,087.18 | 4,094.59 | 4,063.76 |
| 2021 | 4,059.51 | 4,063.00 | 4,076.33 | 4,072.03 |
| 2022 | 4,063.26 | 4,056.07 | 4,095.24 | 4,128.72 |
| **2023** | **4,083.99** | **4,103.64** | | |

*ប្រភព: ធនាគារជាតិនៃកម្ពុជា*

*រូបភាព ២÷ ស្ថានភាពអតិផរណា និងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)*




ប្រភពៈ ធនាគារជាតិនៃកម្ពុជា

## ២.៣. ស្ថានភាពហិរញ្ញវត្ថុសាធារណៈ

*តារាង ៤÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) (គិតជាប៊ីលានរៀល)*

| បរិយាយ | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| **I. ចំណូលក្នុងប្រទេស** | **5,448.66** | **7,384.88** | **6,418.22** | **-13.1%** |
| **១. ចំណូលចរន្ត** | **5,439.60** | **7,376.42** | **6,401.44** | **-13.2%** |
| ក. ចំណូលសារពើពន្ធ | 5,184.16 | 6,966.68 | 5,687.70 | -18.4% |
| ខ. ចំណូលមិនមែនសារពើពន្ធ | 255.44 | 409.74 | 713.74 | 74.2% |
| **២. ចំណូលមូលធន** | **9.06** | **8.46** | **16.79** | **98.4%** |
| **II. ចំណាយសរុប** | **5,370.01** | **5,978.48** | **7,507.38** | **25.6%** |
| **១. ចំណាយចរន្ត** | **3,685.35** | **3,712.86** | **4,500.54** | **21.2%** |
| ក. ការពារ និងសន្តិសុខជាតិ | 982.59 | 997.12 | 1,153.66 | 15.7% |
| ខ. រដ្ឋបាលស៊ីវិល | 2,658.30 | 2,691.41 | 3,305.33 | 22.8% |
| គ. ចំណាយការប្រាក់ | 44.45 | 24.33 | 41.55 | 70.8% |

| បរិយាយ | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| **២. ចំណាយមូលធន** | **1,684.66** | **2,265.62** | **3,006.84** | **32.7%** |
| ឱនភាពចរន្ត (សាច់ប្រាក់) | 1,754.25 | 3,663.56 | 1,900.90 | -48.1% |
| ឱនភាពទូទៅ (សាច់ប្រាក់) | 78.65 | 1,406.40 | (1,089.16) | -177.4% |
| **III. ហិរញ្ញប្បទាន** | **(78.65)** | **(1,406.40)** | **1,089.16** | **-177.4%** |
| ១. ហិរញ្ញប្បទានក្រៅស្រុក | 677.23 | 1,597.62 | 2,909.50 | 82.1% |
| ២. ហិរញ្ញប្បទានក្នុងស្រុក | 106.20 | (54.26) | 17.05 | -131.4% |
| ៣. ប្រតិបត្តិការកំពុងដំណើរការ | (862.08) | (2,949.75) | (1,837.40) | -37.7% |

ប្រភព៖ អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៣៖ស្ថានភាពហិរញ្ញវត្ថុសាធារណៈ (គិតជាប៊ីលានរៀល)*




ប្រភព៖ អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៤. ស្ថានភាពរូបិយវត្ថុ និងឥណទាន

*តារាង ៥÷ ស្ថានភាពរូបិយវត្ថុ (គិតជាប៊ីលានរៀល)*

| បរិយាយ | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **62,835.14** | **46,705.16** | **46,825.26** | **0.3%** |
| ឥណទេយ្យពីអនិវាសជន | 101,619.98 | 97,797.61 | 99,161.14 | 1.4% |
| ទ្រព្យអកម្មចំពោះអនិវាសជន | (38,784.84) | (51,092.45) | (52,335.88) | 2.4% |
| **ឥណទេយ្យក្នុងស្រុក** | **146,697.61** | **186,982.35** | **208,949.94** | **11.7%** |
| ឥណទេយ្យសុទ្ធចំពោះរដ្ឋាភិបាល | (22,556.42) | (21,907.75) | (22,415.13) | 2.3% |
| ឥណទេយ្យចំពោះរដ្ឋាភិបាល | 87.02 | 98.31 | 274.86 | 179.6% |
| ទ្រព្យអកម្មរដ្ឋាភិបាល | (22,643.45) | (22,006.06) | (22,689.99) | 3.1% |
| ឥណទេយ្យសុទ្ធចំពោះវិស័យផ្សេងៗ | 169,254.03 | 208,890.10 | 231,365.06 | 10.8% |
| ឥណទេយ្យចំពោះរដ្ឋាភិបាលថ្នាក់ក្រោមជាតិ | - | - | - | - |
| ឥណទេយ្យចំពោះគ្រឹះស្ថានសាធារណៈមិនមែនហិរញ្ញវត្ថុ | 36.24 | 38.12 | 3.48 | -90.9% |
| ឥណទេយ្យចំពោះវិស័យឯជន | 169,217.79 | 208,851.98 | 231,361.58 | 10.8% |
| **ទ្រព្យអកម្មជារូបិយវត្ថុទូទៅ (M2)** | **147,952.45** | **167,112.21** | **182,492.82** | **9.2%** |
| *ក្នុងនោះជារូបិយបណ្ណបរទេស* | 122,448.58 | 140,511.50 | 151,446.41 | 7.8% |
| រូបិយវត្ថុ (M1) | 42,091.11 | 44,082.25 | 42,820.89 | -2.9% |
| រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ | 14,758.99 | 13,855.62 | 14,966.10 | 8.0% |
| ប្រាក់បញ្ញើចរន្ត | 27,332.11 | 30,226.63 | 27,854.79 | -7.8% |
| ប្រាក់បញ្ញើផ្សេងទៀត | 105,861.34 | 123,029.96 | 139,671.93 | 13.5% |
| មូលបត្រមិនមែនភាគហ៊ុន | - | - | - | - |
| **ទុនបម្រុងជារូបិយបណ្ណបរទេសដុល (លានដុល្លារអាមេរិក)** | **20,233.82** | **19,525.17** | **18,375.78** | **-5.9%** |

*ប្រភពៈ ធនាគារជាតិនៃកម្ពុជា*

## រូបភាព ៤÷ស្ថានភាពរូបិយវត្ថុប្រចាំត្រីមាស




ប្រភពៈ ធនាគារជាតិនៃកម្ពុជា

## តារាង ៦÷ ស្ថានភាពឥណទានផ្តល់ដោយធនាគារពាណិជ្ជ (គិតជាប៊ីលានរៀល)

| បរិយាយ | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| គ្រឹះស្ថានហិរញ្ញវត្ថុ | 6,346.90 | 7,854.31 | 8,044.26 | 2.4% |
| ធនាគារជាតិនៃកម្ពុជា | - | - | - | - |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | 4,649.69 | 5,774.80 | 5,935.33 | 2.8% |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត | 1,697.22 | 2,079.51 | 2,108.93 | 1.4% |
| គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ | 102,588.09 | 128,970.95 | 143,176.03 | 11.0% |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 10,525.47 | 13,944.90 | 15,679.52 | 12.4% |
| ឧស្សាហកម្មរ៉ែ | 629.83 | 937.84 | 1,073.35 | 14.4% |
| កម្មន្តសាល | 5,792.06 | 7,202.12 | 8,681.03 | 20.5% |
| ការផ្គត់ផ្គង់សេវាសាធារណៈ | 1,856.76 | 1,833.08 | 2,254.41 | 23.0% |
| សំណង់ | 13,973.17 | 16,772.98 | 18,318.03 | 9.2% |
| ការជួញដូរដុំ | 13,888.04 | 17,065.46 | 18,364.72 | 7.6% |
| ការជួញដូររាយ | 22,205.78 | 28,146.82 | 31,872.41 | 13.2% |
| សណ្ឋាគារ និងភោជនីយដ្ឋាន | 6,623.46 | 7,865.42 | 8,151.37 | 3.6% |

| បរិយាយ | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | 3,728.81 | 4,763.79 | 5,104.12 | 7.1% |
| បណ្តាញព័ត៌មាន និងទូរគមនាគមន៍ | 1,284.97 | 1,009.40 | 1,049.74 | 4.0% |
| អាជីវកម្មជួល និងភតិសន្យាប្រតិបត្តិការ | 2,639.65 | 2,753.89 | 2,326.82 | -15.5% |
| ការជួញដូរអចលនទ្រព្យ | 11,945.38 | 16,913.85 | 19,616.48 | 16.0% |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗ | 7,494.71 | 9,761.39 | 10,684.05 | 9.5% |
| តម្រូវការផ្ទាល់ខ្លួន | 33,671.38 | 41,178.73 | 44,490.43 | 8.0% |
| ការឱ្យខ្ចីជាបុគ្គល | 14,370.20 | 16,007.49 | 15,287.63 | -4.5% |
| ការឱ្យខ្ចីតាមបណ្ណឥណទាន | 272.04 | 416.09 | 578.08 | 38.9% |
| ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | 19,029.14 | 24,755.14 | 28,624.72 | 15.6% |
| ឥណទានផ្សេងៗ | 1,370.87 | 2,285.81 | 2,833.31 | 24.0% |
| **សរុប** | **143,977.24** | **180,289.80** | **198,544.02** | **10.1%** |
| *ក្នុងនោះជារៀល* | *16,003.85* | *19,844.10* | *21,371.93* | *7.7%* |

*ប្រភព: ធនាគារជាតិនៃកម្ពុជា*

*រូបភាព ៥÷ស្ថានភាពឥណទានផ្តល់ដោយធនាគារពាណិជ្ជប្រចាំត្រីមាស*




ប្រភព: ធនាគារជាតិនៃកម្ពុជា

*តារាង ៧÷ ស្ថានភាពឥណទានផ្តល់ដោយមីក្រូហិរញ្ញវត្ថុ (គិតជាប៊ីលានរៀល)*

| បរិយាយ | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| ស្ថាប័នហិរញ្ញវត្ថុ | 23.82 | 40.10 | 30.40 | -24.2% |
| កសិកម្ម | 5,764.53 | 6,348.12 | 7,042.07 | 10.9% |
| កម្មន្តសាល | 418.72 | 622.57 | 763.55 | 22.6% |
| ពាណិជ្ជកម្ម | 6,493.17 | 8,279.06 | 9,291.87 | 12.2% |
| គ្រួសារ | 10,456.25 | 11,717.01 | 13,725.41 | 17.1% |
| សេវាកម្ម | 4,355.45 | 4,944.81 | 5,375.24 | 8.7% |
| ដឹកជញ្ជូន | 1,750.40 | 1,671.41 | 1,672.16 | 0.0% |
| សំណង់ | 1,175.50 | 1,645.97 | 1,757.06 | 6.7% |
| ឥណទានផ្សេងៗ | 352.40 | 461.33 | 539.95 | 17.0% |
| **សរុប** | **30,790.26** | **35,730.39** | **40,197.71** | **12.5%** |

ប្រភព: ធនាគារជាតិនៃកម្ពុជា

*រូបភាព ៦÷ចំណែក នៃឥណទានតាមវិស័យផ្តល់ដោយមីក្រូហិរញ្ញវត្ថុប្រចាំត្រីមាស*




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៥. ស្ថានភាពពាណិជ្ជកម្ម

*តារាង ៨÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាលានដុល្លារអាម៉េរិក)*

| មុខទំនិញ | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| ថ្នាំពេទ្យ | 97.21 | 123.96 | 99.95 | -19.4% |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 134.75 | 132.85 | 127.81 | -3.8% |
| ស្ករស និងប៊ីចេង | 15.45 | 20.05 | 26.27 | 31.0% |
| ប្រេងឆា និងអាហារផ្សេងៗ | 128.76 | 159.98 | 167.97 | 5.0% |
| គ្រឿងសំណង់ | 401.39 | 511.32 | 503.55 | -1.5% |
| គ្រឿងអេឡិចត្រូនិក | 142.29 | 199.35 | 275.42 | 38.2% |
| វាយនភណ្ឌនិងសម្លៀកបំពាក់ | 1,436.50 | 1,624.12 | 1,383.01 | -14.8% |
| យានយន្ត | 273.25 | 373.49 | 243.90 | -34.7% |
| គ្រឿងបន្លាស់ថយន្ត | 5.40 | 5.17 | 7.06 | 36.6% |
| បរិក្ខារត្រជាក់ | 17.66 | 19.47 | 25.03 | 28.5% |
| ប្រេងឥន្ធនៈ | 438.58 | 731.07 | 595.79 | -18.5% |
| មាស | 1,015.94 | 1,572.18 | - | -100.0% |
| ជីកសិកម្ម | 92.70 | 88.18 | 95.48 | 8.3% |
| ផ្សេងៗ | 2,461.90 | 2,857.61 | 2,817.81 | -1.4% |
| **សរុប** | **6,661.78** | **8,418.80** | **6,369.05** | **-24.3%** |

ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៧÷ ទំហំនាំចូលគ្រឿងសំណង់, ប្រេងឥន្ធនៈ, យានយន្ត, វាយនភណ្ឌនិងសម្លៀកបំពាក់ (លានដុល្លារអាមេរិក)*




ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៨÷ ស្ថានភាពនាំចូលពីទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)*




ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*តារាង ៩÷ មុខទំនិញនាំចេញ (គិតជាលានដុល្លារអាមេរិក)*

| មុខទំនិញ | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| សម្លៀកបំពាក់ | 1,461.77 | 2,372.99 | 1,999.78 | -15.7% |
| ស្បែកជើង | 321.56 | 425.19 | 376.85 | -11.4% |
| កាបូប | 304.89 | 504.93 | 434.51 | -13.9% |
| វាយនភណ្ឌផ្សេងៗ | 58.79 | 62.57 | 53.47 | -14.5% |
| គ្រឿងអេឡិចត្រូនិក និងភាគបំណែក | 47.34 | 48.18 | 51.90 | 7.7% |
| គ្រឿងបន្លាស់រថយន្ត | 22.03 | 39.92 | 57.94 | 45.1% |
| កង់ | 139.28 | 224.87 | 136.66 | -39.2% |
| ឈើមូល | 1.98 | 0.94 | 0.86 | -8.9% |
| ឈើកែច្នៃ (Veneer) | 0.54 | 0.46 | 0.00 | -100.0% |
| ក្តារបន្ទះ | 61.96 | 54.00 | 48.34 | -10.5% |
| ឈើកែច្នៃផ្សេងទៀត | 61.10 | 65.90 | 76.85 | 16.6% |
| អង្ករ | 93.89 | 98.87 | 103.23 | 4.4% |
| ដំឡូងមី | 54.11 | 130.98 | 63.52 | -51.5% |
| ពោតក្រហម | 0.39 | 5.68 | 4.20 | -26.1% |
| សណ្តែក | 0.11 | 0.23 | 0.29 | 25.6% |
| ចេក | 67.49 | 70.31 | 47.40 | -32.6% |
| ស្វាយ | 31.76 | 25.33 | 38.58 | 52.3% |
| ស្វាយចន្ទី | 109.01 | 109.80 | 161.20 | 46.8% |
| កៅស៊ូ | 64.53 | 78.49 | 70.51 | -10.2% |
| ស្ករស | 7.92 | 20.14 | 45.70 | 126.9% |
| ផលិតផលជលផល | 0.10 | 0.07 | 0.11 | 66.5% |
| កសិផលផ្សេងទៀត | 142.61 | 97.74 | 169.29 | 73.2% |
| បារី | 2.26 | 1.61 | 1.98 | 23.1% |
| ខ្សែភ្លើង និងបង្គុំខ្សែភ្លើង | 54.24 | 85.94 | 74.23 | -13.6% |
| សំបកកំប៉ុង និងគម្របកំប៉ុង | 0.03 | 0.05 | 0.06 | 24.0% |
| មាស | 66.94 | 49.50 | 456.35 | 821.8% |
| ផ្សេងៗ | 771.24 | 1,087.60 | 1,598.65 | 47.0% |
| **សរុប** | **3,947.87** | **5,662.30** | **6,072.47** | **7.2%** |

ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ៩÷ ស្ថានភាពមុខទំនិញនាំចេញសំខាន់ៗ (គិតជាលានដុល្លារអាមេរិក)*




ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព ១០÷ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)*




ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៦. ស្ថានភាពវិនិយោគឯកជន

*តារាង ១០÷ ស្ថិតិវិនិយោគវិស័យឯកជន (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគ | ឯកតា | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| **គម្រោងវិនិយោគសរុប** | **គម្រោង** | **38** | **51** | **74** | **45.1%** |
| **បង្កើតការងារសរុប** | **កន្លែង** | **20,793** | **33,324** | **78,107** | **134.4%** |
| **ទុនវិនិយោគសរុប** | **លានដុល្លារអាមេរិក** | **638.33** | **465.47** | **760.17** | **63.3%** |
| ការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស | | | | | |
| គម្រោងវិនិយោគ | គម្រោង | 7 | 11 | 19 | 72.7% |
| បង្កើតការងារ | កន្លែង | 3,638 | 4,396 | 17,631 | 301.1% |
| ទុនវិនិយោគលើវិស័យ | លានដុល្លារអាមេរិក | 376.30 | 59.07 | 259.53 | 339.4% |
| កសិកម្ម | លានដុល្លារអាមេរិក | - | - | - | - |
| ថាមពល | លានដុល្លារអាមេរិក | - | - | - | - |
| ឧស្សាហកម្ម | លានដុល្លារអាមេរិក | 376.30 | 59.07 | 259.53 | 339.4% |
| សេវាកម្ម | លានដុល្លារអាមេរិក | - | - | - | - |
| ទេសចរណ៍ | លានដុល្លារអាមេរិក | - | - | - | - |
| ការវិនិយោគក្រៅតំបន់សេដ្ឋកិច្ចពិសេស | | | | | |
| គម្រោងវិនិយោគ | គម្រោង | 31 | 40 | 55 | 37.5% |
| បង្កើតការងារ | កន្លែង | 17,155 | 28,928 | 60,476 | 109.1% |
| ទុនវិនិយោគលើវិស័យ | លានដុល្លារអាមេរិក | 262.03 | 406.40 | 500.63 | 23.2% |
| កសិកម្ម | លានដុល្លារអាមេរិក | - | 4.30 | 151.76 | 3427.7% |
| ថាមពល | លានដុល្លារអាមេរិក | - | - | - | - |
| ឧស្សាហកម្ម | លានដុល្លារអាមេរិក | 258.14 | 402.10 | 348.87 | -13.2% |
| សេវាកម្ម | លានដុល្លារអាមេរិក | 3.89 | - | - | - |
| ទេសចរណ៍ | លានដុល្លារអាមេរិក | - | - | - | - |

ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC), សម្គាល់ការអនុញ្ញាតវិនិយោគសរុប ដោយរួមបញ្ចូលការពង្រីកគម្រោងក្រៅតំបន់សេដ្ឋកិច្ចពិសេស

*រូបភាព ១១÷ស្ថានភាពវិនិយោគឯកជន*




ប្រភព: ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)

## ២.៧. ស្ថានភាពទេសចរណ៍

*តារាង ១១÷ ចំនួនភ្ញៀវទេសចរអន្តរជាតិ*

| បរិយាយ | ឯកតា | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| តាមផ្លូវអាកាស | នាក់ | 12,714 | 153,661 | 431,253 | 180.7% |
| ភ្នំពេញ | នាក់ | 11,374 | 131,669 | 335,823 | 155.1% |
| សៀមរាប | នាក់ | 2 | 16,928 | 91,547 | 440.8% |
| កងកេង | នាក់ | 1,338 | 5,064 | 3,883 | -23.3% |
| តាមផ្លូវគោក និងផ្លូវទឹក | នាក់ | 18,945 | 193,555 | 857,140 | 342.8% |
| ផ្លូវគោក | នាក់ | 18,943 | 190,981 | 843,025 | 341.4% |
| ផ្លូវទឹក | នាក់ | 0 | 2,574 | 14,115 | 448.4% |
| **សរុប** | **នាក់** | **31,659** | **347,216** | **1,288,393** | **271.1%** |

ប្រភព: ក្រសួងទេសចរណ៍

*រូបភាព ១២៖ កំណើនភ្ញៀវទេសចរអន្តរជាតិ (គិតជា %)*




ប្រភព៖ ក្រសួងទេសចរណ៍

*រូបភាព ១៣៖ កំណើនភ្ញៀវទេសចរអន្តរជាតិពីតំបន់នីមួយៗ (គិតជា %)*




ប្រភព៖ ក្រសួងទេសចរណ៍

## ២.៨. ស្ថានភាពសំណង់

*តារាង ១២÷ សំណង់ទូទាំងប្រទេស*

| បរិយាយ | ឯកតា | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|---|
| | | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| សំណង់សាធារណៈ | គម្រោង | 9 | 16 | 21 | 31.3% |
| សំណង់លំនៅឋាន និងភូមិគ្រឹះ | គម្រោង | 1,050 | 890 | 677 | -23.9% |
| សំណង់ឧស្សាហកម្ម | គម្រោង | 26 | 30 | 58 | 93.3% |
| សំណង់ពាណិជ្ជកម្ម | គម្រោង | 72 | 52 | 50 | -3.8% |
| សំណង់ទេសចរណ៍ | គម្រោង | 11 | 11 | 20 | 81.8% |
| សំណង់វិនិយោគផ្សេងៗ | គម្រោង | 1 | - | - | - |
| **សរុប** | **គម្រោង** | **1,169** | **999** | **826** | **-17.3%** |
| **តម្លៃ** | **លានដុល្លារអាមេរិក** | **862.65** | **640.60** | **1,474.95** | **130.2%** |

ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

*រូបភាព ១៤÷ ចំណែកនៃផ្ទៃក្រឡាសាងសង់តាមប្រភេទ (គិតជា %)*




ប្រភព: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង ១៣÷ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|---|---|
| | | | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| អង្ករ (បាក់៥%) | ដុល្លារអាម៉េរិក/តោន | បាងកក | 484.67 | 446.33 | 508.33 | 13.9% |
| ប្រេងឆៅ | ដុល្លារអាម៉េរិក/ធុង | ក្រុងឡុងដ៍ | 67.05 | 110.10 | 76.62 | -30.4% |
| កៅស៊ូ | ដុល្លារអាម៉េរិក/តោន | សិង្ហបុរី | 1,657.27 | 1,652.10 | 1,342.47 | -18.7% |
| មាស | ដុល្លារអាម៉េរិក/អោន | ក្រុងឡុងដ៍ | 1,991.26 | 2,056.01 | 2,170.44 | 5.6% |
| ពោតក្រហម | ដុល្លារអាម៉េរិក/តោន | ស៊ីកាហ្គោ | 288.70 | 342.91 | 275.37 | -19.7% |
| សណ្តែកសៀង | ដុល្លារអាម៉េរិក/តោន | ស៊ីកាហ្គោ | 619.54 | 727.31 | 600.61 | -17.4% |
| ប្រេងដូង | ដុល្លារអាម៉េរិក/តោន | រ៉ុតធើដាំ | 1,681.85 | 1,869.48 | 1,044.79 | -44.1% |
| ស្ករស | ដុល្លារអាម៉េរិក/តោន | ក្រុងឡុងដ៍ | 393.57 | 348.08 | 355.70 | 2.2% |

ប្រភព: គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*រូបភាព១៥ ÷ ទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស)*




ប្រភព: គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*តារាង ១៤÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស, ឆ្នាំគោល ២០១០=១០០)*

| មុខទំនិញ | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| **មិនមែនថាមពល** | 112.73 | 133.79 | 112.40 | -16.0% |
| ផលិតផលកសិកម្ម | 108.51 | 132.38 | 114.95 | -13.2% |
| ម្ហូបអាហារ | 122.60 | 156.47 | 132.95 | -15.0% |
| ឈើ | 91.60 | 81.20 | 79.90 | -1.6% |
| លោហៈធាតុ | 121.80 | 125.42 | 103.04 | -17.8% |
| ជីគីមី | 109.13 | 233.10 | 148.91 | -36.1% |

ប្រភព: គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*រូបភាព១៦ ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ជាមធ្យមប្រចាំត្រីមាស, ឆ្នាំគោល ២០១០=១០០)*




*ចំណាំ÷អាហារ (ធញ្ញជាតិ, ប្រេងឆា និងអាហារផ្សេងៗ), ភេសជ្ជៈ (កាកាវ, កាហ្វេ និងតែ), វត្ថុធាតុដើម (ឈើមូល, កប្បាស, កៅស៊ូ និងថ្នាំជក់)*

ប្រភព: គេហទំព័រធនាគារពិភពលោក (www.worldbank.org)

*តារាង ១៥÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (ជាមធ្យមប្រចាំត្រីមាស)*

| រូបិយបណ្ណ | ត្រីមាសទី២ | | | ការប្រែប្រួល |
|---|---|---|---|---|
| | ២០២១ | ២០២២ | ២០២៣ | ២០២៣ |
| ជប៉ុន (Yen) | 109.80 | 131.50 | 140.29 | 6.7% |
| ហុងកុង (Dollar) | 7.76 | 7.85 | 7.84 | -0.1% |
| សិង្ហបុរី (Dollar) | 1.33 | 1.38 | 1.35 | -2.5% |
| ម៉ាឡេស៊ី (Ringgit) | 4.13 | 4.38 | 3.49 | -20.2% |
| ហ្វីលីពីន (Peso) | 48.17 | 53.25 | 38.44 | -27.8% |
| ថៃ (Baht) | 31.43 | 34.58 | 34.80 | 0.6% |
| ឥណ្ឌូនេស៊ី (Rupiah) | 14,418.83 | 14,649.23 | 14,882.53 | 1.6% |
| កូរ៉េខាងត្បូង (Won) | 1,118.79 | 1,265.29 | 1,324.74 | 4.7% |
| តៃវ៉ាន់ (Dollar) | 27.81 | 29.39 | 30.78 | 4.8% |
| ចិន (Yuan Renminbi) | 6.43 | 6.66 | 7.08 | 6.4% |
| ឡាវ (Kip) | 9,315.67 | 13,295.80 | 17,839.23 | 34.2% |
| វៀតណាម (Dong) | 23,021.17 | 23,136.13 | 23,500.07 | 1.6% |
| ឥណ្ឌា (Rupee) | 73.49 | 77.52 | 82.15 | 6.0% |
| រុស្ស៊ី (Ruble) | 73.56 | 62.52 | 82.09 | 31.3% |
| អូស្ត្រាលី (Dollar) | 1.30 | 1.42 | 1.52 | 7.2% |
| អង់គ្លេស (Pound) | 0.72 | 0.80 | 0.80 | -0.8% |
| អឺរ៉ុប (Euro) | 0.83 | 0.95 | 0.92 | -2.2% |

ប្រភព៖ គេហទំព័រអូអែនដា (www.oanda.com)